**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពុទ្ធមណ្ឌលវិបស្សនាធុរៈ**
**នៃព្រះរាជាណាចក្រកម្ពុជា**

# វតេនបដោតជាតក

## អច្ឆរិយំទំទុក្ខត្ថិ ឥទំសត្ថាជេតវនេ
## វិហរន្តោមាតុបោសកំ ភិក្ខុំអារព្ភកថេសិ

សត្ថា រីសម្តេចព្រះបរមសាស្តាចារ្យកាលព្រះអង្គគង់នៅក្នុងជេតវនមហាវិហារ ទ្រង់ប្រារព្ធនូវភិក្ខុ ១ រូបជាអ្នកចិញ្ចឹមមាតា ហើយទ្រង់សម្តែងធម្មទេសនានេះមានពាក្យថា អច្ឆរិយំរតីទំទុក្ខំ ដូច្នេះជាដើម រឿងនេះមានសេចក្តីពិស្តារប្រហែលគ្នានឹងសាមជាតក ដែលមានមកក្នុងគម្ពីរទេសជាតកឯណោះ ក្នុងទីនេះមានសេចក្តីសង្ខេបដូចនឹងពោលតទៅនេះ ។

សេចក្តីខាងដើមរឿងនេះថា តាំងអំពីភិក្ខុនោះបានឧបួសមទាហើយវេលាណា ក៏តែងតែស្វែងរកនូវបិណ្ឌបាតមកចិញ្ចឹមមាតារបស់ខ្លួន ទាល់តែភិក្ខុទាំងឡាយនាំគ្នាតិះដៀលលើកទោសថា ធម្មតាអ្នកបួសហើយទៅខំស្វែងរកអាហារបិណ្ឌបាតមកចិញ្ចឹមគ្រហស្ថនោះមិនសមគួរឡើយ ពាក្យទាំងនេះមិនបាត់ស្ងាត់ក៏ជ្រួតជ្រាបដល់ព្រះសោតទិព្វថ្លៃនៃព្រះបរមសាស្តាចារ្យទើបទ្រង់មានពុទ្ធភាសិតត្រាស់ថា នែភិក្ខុទាំងឡាយកុំបៀតបៀនមើលងាយនូវភិក្ខុដែលជាអ្នកចិញ្ចឹមមាតានេះឡើយអ្នកប្រាជ្ញទាំងឡាយអំពីបុរាណមុននាយ ក៏តែងទំនុកបម្រុងមាតារបស់ខ្លួនដោយភេទជាអ្នកបួសដូចយ៉ាងហ្នឹងដែរ ត្រាស់ដូច្នេះហើយព្រះអង្គក៏ទ្រង់ស្ងៀមនៅដោយតុណ្ហីភាព ទើបភិក្ខុទាំងឡាយនោះមានចេតនាប្រាថ្នាចង់ដឹងរឿងរ៉ាវនោះដោយពិស្តារ ហើយក៏ក្រាបបង្គំទូលអារាធនាសូមឲ្យព្រះអង្គសម្តែងថ្លែងធម្មទេសនាតទៅ ឯព្រះបរមគ្រូក៏ទ្រង់យឹតយោងទាញយករឿងរ៉ាវដែលកន្លងទៅហើយនោះមកសម្តែងជាទីសណ្តាប់ឲ្យភិក្ខុ
ទាំងឡាយនោះស្តាប់ក្នុងកាលគ្រានោះឯង ។

## អតីតេភិក្ខវេ មេឃវតិនគរេមហារថោនាមរាជារជ្ជំការេសិ

សេចក្តីថា នែភិក្ខុទាំងឡាយកាលដែលកន្លងទៅហើយនោះ មានព្រះមហាក្សត្រអង្គ ១ ទ្រង់ព្រះនាមថា សិរិរតនអាភា គ្រានោះព្រះបរមពោធិសត្តស្តេចធ្វើចុត្យាការកិច្ចអំពីទេវលោកក្នុងជាន់តុសិត ចុះមកកាន់យកបដិសន្ធិក្នុងគភ៌នៃព្រះអគ្គមហេសីអង្គនោះ ឯព្រះអគ្គមហេសីនោះលុះទ្រង់គភ៌បរិបូណ៌ហើយ ក៏បណ្តាលឲ្យមានព្រះហឫទ័យប្រាថ្នាចង់ចេញទៅក្រសាលលេងក្នុងព្រះរាជឧទ្យានពន់ពេកណាស់ ទើបទូលព្រះរាជស្វាមីឲ្យស្តេចជ្រាបឯសម្តេចព្រះមហារថរាជជាព្រះស្វាមីស្តេចបានជ្រាបហើយទើបស្តេចទ្រង់ត្រាស់បង្គាប់ឲ្យហៅនូវឧយ្យានបាល គឺអ្នករក្សាឧទ្យានឲ្យចូលមកគាល់ ហើយទ្រង់ត្រាស់បង្គាប់ថា នែនាយឧទ្យានចូរអ្នក

ទាំងឡាយចាត់ការតាក់តែងសម្អាតនូវរាជឧទ្យាននោះឲ្យល្អប្រពៃ ឯនាយឧទ្យាននោះក៏ទទួលព្រះរាជតម្រាស់ហើយតាំងរៀបតាក់តែងតាមព្រះរាជអាជ្ញាបង្គាប់ ស្រេចហើយទើបយកសេចក្តីក្រាបបង្គំទូល លុះដល់ថ្ងៃដែលស្តេចនឹងទ្រង់ព្រះរាជដំណើរទៅនោះ ព្រះមហាក្សត្រនិងព្រះរាជទេវីព្រមទាំងសេវកាមាត្យមុខមន្ត្រីនិងរាជបរិវារដ៏ច្រើន ស្តេចក៏ទៅស្ថិតនៅក្នុងព្រះរាជឧទ្យានហើយទ្រង់ទតព្រះនេត្រនិងទ្រង់ក្រសាលសម្រាន្តតាមព្រះរាជហឫទ័យប្រាថ្នា តាំងអំពីវេលាព្រឹករហូតដល់ព្រះអាទិត្យអស្តង្គតទៅ ព្រះមហាក្សត្រព្រមទាំងព្រះរាជទេវីមិនអាចនឹងស្តេចចូលទៅក្នុងព្រះនគរបានឡើយ ព្រោះហួសវេលាស្តេចក៏ទ្រង់ផ្ទំនៅក្នុងឧទ្យាននោះអស់រាត្រី ១ ។

ក្នុងថ្ងៃនោះព្រះបរមរាជានិងអគ្គមហេសី ស្តេចក៏ផ្ទំរួមសេយ្យាសនជាមួយគ្នាទាំងពីរព្រះអង្គ លុះដល់ពេលបច្ចុសសម័យវេលាជិតព្រឹកឡើង ព្រះរាជទេពីនាងទ្រង់សុបិននិមិត្តយល់សប្តិថាដូច្នេះ មានបុរសម្នាក់មានកាយដ៏ខ្មៅភ្នែកក្រហម សក់ក្រហម ស្លៀកសំពត់មានពណ៌ក្រហម ដៃកាន់នូវអាវុធមានមុខដ៏មុតថ្លា ដើរមកពីទិសបស្ចិម តម្រង់ចូលមកកាន់ទីល្វែងដែលព្រះរាជទេវីនាងផ្ទំ ហើយក៏ចាប់នូវផ្នួងព្រះកេសានៃព្រះរាជទេវីទាញផ្តួលផ្តេកព្រះអង្គនាងទៅលើផែនដីឆ្កៀលខ្វេះយកព្រះនេត្រទាំងពីរហើយកាត់ផ្តាច់នូវព្រះហស្តខាងស្តាំ រួចពុះទម្លាយនូវដើមទ្រូង ត្រងយកនូវតំណក់លោហិតដែលហូរចេញមកទុកទើបរូងយកសាច់បេះដូងបានហើយ ក៏បែមុខចំពោះទៅកាន់បស្ចិមទិសហើយចៀសចេញទៅ ។

ឯព្រះរាជទេវីនាងក៏មានព្រះហឫទ័យញាប់ញ័រតក់ស្លុតអំពីមរណភ័យនោះក្រៃពេកណាស់ ក៏ស្ទុះក្រោកឡើងដោយរហ័សទើបដឹងព្រះស្មារតីច្បាស់ប្រាកដ ថាឱខ្លួនអញយល់សប្តិទេអ្ហះ ហើយនាងក៏ក្រោកឡើងរំពឹងគឹតថា សុបិនដែលអាត្មាអញឃើញនេះជាសុបិនលាមកអាក្រក់សល់ខ្នាត សេចក្តីអន្តរាយនឹងមានដល់ខ្លួនអញ ដោយហេតុផលនៃសុបិននេះមិនខានឡើយ លុះគិតដូច្នេះហើយទើបក្រាបបង្គំទូលនូវរឿងនេះឲ្យព្រះរាជស្វាមីស្តេចទ្រង់ជ្រាប – លុះព្រះមហាក្សត្រស្តេចជ្រាបហើយទ្រង់ត្រាស់ប្រាប់នូវដំណើរសុបិននោះ ដល់ហោរាដែលជាអ្នកទំនាយនូវសុបិននិមិត្តថ្វាយ ឯហោរាទាំងឡាយនោះបានយល់ច្បាស់ក្នុងសុបិននោះហើយទើបយកសេចក្តីក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព ឯសុបិនដែលព្រះរាជទេវីទ្រង់យល់នេះ ទំនាយថាព្រះករុណាជាម្ចាស់ជីវិតនិងព្រះរាជទេពីមុខជានឹងព្រាត់ប្រាសចាកគ្នាដោយផលនៃសុបិននោះ មិនខានឡើយ សូមទ្រង់ជ្រាប ។

ព្រះមហាក្សត្រនិងព្រះអគ្គមហេសីស្តេចទ្រង់ព្រះសណ្តាប់ទំនាយនោះហើយព្រះអង្គក៏មានព្រះរាជហឫទ័យរន្ធត់ញាប់ញ័រព្រោះភ័យខ្លាចសេចក្តីព្រាត់ប្រាសបែកគ្នានោះលើសប្រមាណទើបទ្រង់សួរទៅហោរនោះថា នែហោរាទាំងឡាយ ហេតុដែលធ្វើឲ្យយើងវិនាសបែកគ្នានោះតើដូចម្តេចខ្លះ ហោរទាំងនោះក៏ក្រាបទូលថា បពិត្រព្រះសម្មតិទេវរាជក្នុងវេលារសៀលថ្ងៃនេះ មហាមេឃនឹងតាំងឡើងដោរដាលជាភ្លៀងធ្លាក់ចុះមកពេញដែនដីនេះ កាលដំបូង

ឡើយមានទឹកប្រមាណត្រឹមករជើងបន្តិចទៅត្រឹមជង្គង់ ត្រឹមចង្កេះ ត្រឹមដោះ ត្រឹមក ត្រឹមក្បាល រហូតដល់ជម្រៅដើមត្នោត ១ និង ៧ ដើមត្នោតឡើងទៅទើបស្តេចទ្រង់សួរតទៅទៀតថា នែអ្នកទាំងឡាយ បើមានហេតុយ៉ាងហ្នឹងហើយ តើយើងត្រូវធ្វើដូចម្តេចទើបបានស្រួល នេមិត្តកោទាំងឡាយក៏ក្រាបទូលថា បពិត្រសម្តេចព្រះបរមមហារាជ រឿងនេះនឹងរកវត្ថុដទៃក្រៅចាកទូកមកជាទីពឹងពំនាក់នោះគ្មានឡើយ គ្រានោះព្រះមហាក្សត្រស្តេចឲ្យហៅនូវជាងឈើទាំងឡាយមក ហើយទ្រង់ត្រាស់បង្គាប់ថា នែអ្នកទាំងឡាយចូរអ្នកទាំងឡាយធ្វើនូវទូកឲ្យបានឆាប់ ហើយចងភ្ជាប់គ្នាស្រេចវេលាណា ចូរអ្នកទាំងឡាយប្រាប់ដល់យើងកុំខាន នាយជាងទាំងឡាយក៏ទទួលព្រះរាជតម្រាស់ហើយក៏តាំងចាត់ចែងការតទូករួចស្រេចហើយទើបក្រាបទូលថ្វាយតាមព្រះរាជបង្គាប់ ។

លុះដល់សាយណ្ហសម័យ (ថ្ងៃរសៀល) ក៏មហាមេឃតាំងដោរបណ្តាលជាភ្លៀងធំធ្លាក់ចុះមកឥតមានដាច់គ្រាប់ឡើយ ឯទឹកភ្លៀងនោះសោតកាន់តែច្រើនកើនឡើងឥតមានអាក់ ទីដំបូងឡើយមានទឹកប្រមាណត្រឹមកជើង យូរបន្តិចទៅមានជម្រៅត្រឹមជង្គង់ ត្រឹមចង្កេះ ជម្រៅដើមត្នោត ១ រហូតដល់ជម្រៅ ៧ ដើមត្នោតឡើងទៅដូចទំនាយ មហាជនទាំងឡាយ បានឃើញទឹកមានជម្រៅប្រមាណ ៧ ដើមត្នោតដូច្នោះហើយ ក៏មានចិត្តរន្ធត់ញាប់ញ័រខ្លាចសេចក្តីស្លាប់តែរាល់គ្នាជាទីបំផុត ហើយក៏ខំស្វែងរកទីពឹងអាស្រ័យ ចំណែកខាងរលកធំ ៗ ក៏បោកបក់ផ្ទប់នូវមហាជនទាំងនោះឲ្យដល់នូវសេចក្តីវិនាសយ៉ាងធំក្នុងជាន់នោះ ឯព្រះបាទមហារថរាជ និងព្រះអគ្គមហេសីក៏ស្តេចខះខំឡើងលើទូកនោះបានហើយ រលកធំក៏បក់ផាត់បន្សាត់នូវរាជនាវានោះឲ្យអណ្តែតត្រឡប់ត្រឡិនទៅតាមខ្សែទឹកព្រះរាជទេវីនាងទ្រង់គភ៌បរិបូណ៌គ្រប់ខែ ហើយជាស្រីប្រកបដោយសេចក្តីភ័យខ្លាចច្រើន មិនអាចនឹងទប់ទល់តម្កល់ខ្លួនបាន នាងក៏ទ្រង់ព្រះកន្សែងខ្លាំង ទាំងទឹកព្រះនេត្រសោតក៏ហូរចេញស្រោចដូចគេស្រប់ព្រះភក្ត្រា ទើបត្រាស់នូវព្រះគាថានេះថា ។

អច្ឆរិយំវតិជំទុក្ខំ          សុខមត្តំនជាយតិ
កាជំជីវាម្ហសេនេវ          អប្បតិដ្ឋេមហណ្ណវេ
អហោអជាថាកប្បណា      លភាម្ហសេមហោឧដឹ
សលិលេអប្បតិដ្ឋស្មឹ        កាជំជីបំលភាម្ហសេ
ជាហន្តំនេវបស្សាមិ        អជាថាមរណញ្ចមេតិ

សេចក្តីថា បពិត្រព្រះសម្មតិទេពព្រះស្វាមី សេចក្តីសុខមាតាថាបន្តិចបន្តួចរបស់យើងមិនមានសោះឡើយ សេចក្តីទុក្ខក្នុងគ្រានេះហើយជាទុក្ខធំធ្ងន់សល់ខ្នាតលើសធម្មតា ជាហេតុគួរសម្បើមជាទីអស្ចារ្យចម្លែកពេកណាស់ យើងទាំងពីរកាលបើចេះតែសាត់ទៅ ៗ ក្នុងទីជ្រៅកណ្តាលចំណោមទឹកធំដែលរកទីជ្រកទីអាស្រ័យមិនមានហើយ ម្តេចឡើយនឹងមានជីវិតរស់

នៅតទៅទៀតបាន ឱយើងទាំងពីរអ្នកជាមនុស្សកំព្រាផុតទីពឹងត្រឹមហ្នឹងហើយ មកបានឯចំណោមទឹកធំនេះជាផ្ទះនៅកាលបើមកនៅក្នុងកណ្តាលទឹកជ្រៅ ដែលប្រាសចាកទីពឹងហើយធ្វើម្តេចឡើយនឹងជួបប្រទះនូវកោះត្រើយឯណាបាន ខ្ញុំនឹងមិនបានឃើញព្រះអង្គតទៅទៀតសេចក្តីស្លាប់របស់ខ្ញុំមុខជារកទីពឹងមិនបាន ។

កាលព្រះរាជទេវីពោលគាថាយ៉ាងនេះហើយ ទើបព្រះបរមក្សត្រាធិរាជលួងលោមប្រលោមព្រះរាជទេវីថា នៃព្រះនាងដ៏ចម្រើន ប្អូនកុំភ័យកុំខ្សឹកខ្សួលឲ្យជ្រុលពេកឡើយ ហេតុអ្វីបានជាបងពោលយ៉ាងហ្នឹង ព្រោះថាសម្បត្តិទាំងពួងដែលមានហើយ ក៏គង់ដល់នូវសេចក្តីវិនាសពុំលែងឡើយ មានវ័យដ៏ចម្រើនក្នុងកាលខាងដើមហើយ តែងនឹងចាស់ជរាគ្រាំគ្រាក្នុងកាលជាទីបំផុត មិនមានរោគាព្យាធិក្នុងកាលខាងដើមហើយតែងនឹងមានជំងឺឈឺចាប់ក្នុងកាលខាងក្រោយ ពុំខានឡើយមានសេចក្តីរស់នៅហើយ គង់នឹងដល់នូវសេចក្តីស្លាប់ក្នុងទីបំផុតជាទំនៀម ព្រះមហាក្សត្រទ្រង់ប្រោសប្រទានឱវាទដល់ព្រះទេពីដូច្នេះហើយទើបព្រះអង្គត្រាស់គាថាដូច្នេះថា:

មាពាឡ្ហំបរិទេវសិ ឯសាលោកស្សធម្មតា
អនិច្ចាវតសំខារា សព្វពុទ្ធេហិទេសិតា
យំកិញ្ចិកុសលំកតំ មយ្ហញ្ចេវតយាកតំ
សព្វហិតញ្ចកុសលំ ចិន្តេព្វហិសោភណេ

សេចក្តីថា ព្រះនាងកុំខ្សឹកខ្សួលអួលអន់ពេកឡើយធ្វើម្តេចសេចក្តីប្រព្រឹត្តទៅរបស់លោកតែងមានជាធម្មតាយ៉ាងហ្នឹងហើយ សំខារធម៌ទាំងឡាយមិនទៀងទាត់ប្រាកដទេ ព្រះពុទ្ធគ្រប់ព្រះអង្គតែងត្រាស់សម្តែងហើយយ៉ាងហ្នឹង កុសលឯណា ១ ដែលព្រះនាងបានសាងសន្សំទុកហើយក្តី ប្រយោជន៍ទាំងពួងដែលព្រះប្អូនបានធ្វើទុកដើម្បីឲ្យបងក្តី ចូរប្អូននឹករឭកត្រង់កុសលទាំងនោះជាចំណែកដ៏ល្អ ។

កាលព្រះបាទមហារថរាជ ស្តេចបានប្រទានឱវាទលួងលោមព្រះរាជទេវីដូច្នោះហើយចំណែកខាងរលកទឹកធំ ៗ នោះក៏បក់បោកខ្លាំងខ្ទប់ចូលមក ឯនាវានោះសោតក៏បែកបាក់ទៅជាចំណែកពីរ ព្រះទេវីក៏មានសេចក្តីភិតភ័យនឹងមរណាសង្គ្រាមនោះឥតឧបមា នឹងនឹករកឧបាយណា ១ មកជួយដោះខ្លួនឲ្យរួចផុតពីសេចក្តីគ្រោះថ្នាក់នេះមិនឃើញឡើយ នាងក៏ទ្រង់ព្រះពិលាបសោយសោក ស្រែកហៅរកព្រះរាជស្វាមីឲ្យជួយដោះនាងអំពីទុក្ខធំ ហើយត្រាស់ព្រះគាថាដូច្នេះថា៖

ឯហិតណ្ហាហិមំទេវ វិប្បំមោចេហិទុក្ខតោ
តយាវិនានជីវាមិ មាមំសជ្ជេថរថេសភ

សេចក្ដីថា បពិត្រព្រះសម្មតិរាជ សូមព្រះអង្គស្ដេចមកជួយខ្ញុំ ចូរដោះខ្ញុំម្ចាស់ឲ្យរួចចាកគ្រោះថ្នាក់ធំក្នុងជាន់នេះឲ្យឆាប់ឲ្យទានផង ឯខ្លួនខ្ញុំម្ចាស់សោតបើវៀរលែងព្រះអង្គហើយ នឹងមិនមានជីវិតតទៅទៀតឡើយ ព្រះអង្គស្ដេចកុំលះបង់ចោលខ្ញុំឡើយណាព្រះករុណា ។

ព្រះបាទសម្ដេចព្រះមហារថរាជ ស្ដេចបានទ្រង់ព្រះសណ្ដាប់សព្ទសំឡេងពិលាបសោយសោកនៃព្រះរាជទេវី ព្រោះសេចក្ដីនិរាសប្រាសព្រាត់ដូច្នោះហើយ ស្ដេចក៏មានព្រះហឫទ័យស្លុតស្លុងភាន់ភាំងព្រះស្មារតីទើបយកព្រះភូសារបស់ព្រះអង្គចងពាត់ព្រះអង្គនឹងព្រះរាជទេវីផ្ដាប់គ្នាយ៉ាងមាំទុកហើយ គ្រានោះព្រះភូសាសាដក ក៏ដាច់ដាចផុតចេញពីគ្នា ហាក់ដូចជាសម្ដែងឲ្យឃើញនូវផលនៃអកុសលកម្មរបស់ព្រះអង្គដែលបានធ្វើរួចហើយអំពីមុន ។

ព្រះមហាក្សត្រនិងព្រះរាជទេពីទាំងពីរព្រះអង្គ ត្រូវរលកទឹកបោកបែកគ្នាទៅតែ ១ ព្រះអង្គ ៗ ។

ពាក្យសួរថា ព្រះមហាក្សត្រនិងព្រះរាជទេវីបានធ្វើនូវអំពើអកុសលអ្វី ទើបបានមកដល់ប្រទះលើសេចក្ដីអន្តរាយដូច្នេះនេះ ។

ពាក្យឆ្លើយថា កាលអំពីជាតិមុននោះព្រះមហាក្សត្រនិងព្រះអគ្គមហេសីទាំងពីរព្រះអង្គនេះ ជាស្ដេចសោយរាជសម្បត្តិនៅក្នុងពារាណសី គ្រាមួយនោះព្រះអង្គទាំងពីរស្ដេចចុះទៅស្រង់ទឹកទៀបឆ្នេរនៃគង្គា ពេលនោះមានសាមណេរមួយអង្គអាយុបាន ៧ ឆ្នាំ អុំទូកបម្រុងចតនៅត្រង់ទីនោះ ក៏ព្រះមហាក្សត្រនិងព្រះទេពី ស្ដេចចង់ក្រសាលសប្បាយហើយទៅធ្វើទូកដែលសាមណេរជិះនោះឲ្យឃ្លេងឃ្លោងលេង ឯសាមណេរនោះសោតក៏ហេតុតែជាមនុស្សក្មេងមានសេចក្ដីភិតភ័យនឹងទូកឃ្លេងឃ្លោងនោះក្រៃពេកណាស់ ក៏ស្រែកដោយសំឡេងឡើងខ្លាំងហេតុតែផលនៃកម្មដែលព្រះមហាក្សត្រនិងព្រះនាងឲ្យសាមណេរនោះភិតភ័យនោះឯងហើយបានជាជាប់តាមមកធ្វើឲ្យព្រះអង្គទាំងពីរព្រាត់ព្រាកចាកគ្នាយ៉ាងនេះ ។

ឯអំពើអាក្រក់សូម្បីមាត្រាថាតូចមួយ ក៏គួរយើងរាល់គ្នាកុំធ្វើឡើយ ព្រោះហេតុហ្នឹងហើយបានជាសម្ដេចព្រះភគវាទ្រង់ត្រាស់ទេសនាហាមឃាត់ទុកថា៖

**ខុទ្ទកញ្ចមិជំកម្មំ ឯតំបត្តោតិមុញ្ចតិ**

**ឧក្កាវំសុករំកម្មំ ឯភវេយ្យកុបាចនំ**

សេចក្ដីថា កម្មនេះតូចតិចពេកណាស់ ចំណែកបុគ្គលអ្នកធ្វើនោះមុកជាមិនដល់នូវផលនៃកម្មនោះឡើយគង់នឹងរបូតរួចផុតទៅទទេ ការងារដែលធ្វើអាក្រក់ក្ដី ល្អក្ដី មុកជាមិនមាន មកអំពីទីណា ១ ឡើយ បុរសប្រុសស្រីកុំមានប្រមាទយ៉ាងនឹងឡើយ ឯការដែលធ្វើអាក្រក់ឬធ្វើល្អនោះសូម្បីបន្តិចបន្តួចក៏គង់សងផលដល់អ្នកដែលធ្វើតាមកំឡាំងមិនលែងឡើយ ដូចជាព្រះបាទមហារថរាជ នឹងនាងសិរិរតនអាភា ដែលធ្វើលេងឲ្យសាមណេរភិតភ័យប៉ុណ្ណឹង ផលនោះក៏អាចសងវិញធ្វើឲ្យព្រាត់ព្រាកចាកគ្នាជាក់ស្ដែងយ៉ាងនេះមិនខាន ។

ឯព្រះរាជទេវីឃ្លាតចាកព្រះរាជស្វាមីហើយក៏អណ្ដែតសាត់ទៅដោយលំដាប់ ៗ ហើយ

បានទៅដល់ទៀបជើងភ្នំចន្ទបពិតនាងក៏ស្តេចឡើងពីទឹកនោះហើយទ្រង់ទតព្រះនេត្ររកមើលទៅក្នុងទិសខាងនេះខាងនោះក៏មិនប្រទះឃើញនូវមនុស្សម្នាឯណាមួយឡើយ ហើយទើបទ្រង់រម្សាយព្រះភូសាសាដក ហាលកម្តៅពាក់កណ្តាល នាងទ្រង់ស្លៀកបិទបាំងព្រះអង្គពាក់កណ្តាល លុះប្រែត្រឡប់ស្ងួតទាំងអស់ហើយ ក៏ទ្រង់ស្លៀកតាមប្រក្រតីធម្មតា ទើបទ្រង់ស្ថិតនៅក្រោមដើមឈើមួយ ពេលនោះព្រះរាជទេវីនាងគង់នៅតែម្នាក់ឯង ជាអ្នកកំព្រាឥតមានគ្នីគ្នាមិត្តសម្លាញ់ឯណា ១ ជាទីពឹងពុំនាក់ឡើយ គួរឲ្យករុណាអាណិតពេកណាស់ នាងក៏ទ្រង់ព្រះពិលាបសោយសោក ទឹកព្រះនេត្រក៏ហូរហៀរស្រក់ស្រោចព្រះភក្ត្រា ហើយនាងមានព្រះរាជសវនីយ៍ពោលនូវព្រះគាថាដូច្នេះថា៖

វិយោគោមេកតោបុព្វេ ណរស្សមិគបក្ខិណោ
តេនកម្មវិចាកេន វិយោគោបតិនាសហា
កជំបស្សសិមំឯកំ មហារាជមហិប្បតិ
អនាថិនានិមេអជ្ជ ឯកិការព្រហារនេ

សេចក្តីថា ការដែលពង្រាត់ពង្រាសមនុស្សនិងសត្វម្រឹគ ឬសត្វស្លាប ទំនងជាអញបានធ្វើហើយក្នុងគ្រាមុនឲ្យគេព្រាត់ព្រាកចាកគូ ឬកូនរបស់គេដឹង លុះដល់មកជាតិនេះ ទើបអញត្រូវព្រាត់ព្រាកចាកព្រះរាជស្វាមីជាទីស្រឡាញ់របស់ខ្លួន ដោយផលនៃកម្មនោះឯងជាប់តាមមកប្រគល់ឲ្យ បពិត្រសម្តេចមហារាជដ៏ទ្រង់នូវអំណាចគ្រប់គ្រងនូវផែនដី ធ្វើម្តេចហើយព្រះអង្គនឹងបានមកជួបឃើញខ្ញុំម្ចាស់ ដែលជាស្រីកំព្រាម្នាក់ឯងក្នុងទីនេះទៀតទៅ ឥឡូវនេះខ្ញុំម្ចាស់ជាស្រីអនាថាត្រមោចនៅតែម្នាក់ឯងក្នុងដង្ហំព្រៃធំរកទីពឹងគ្មានឡើយ មុខជានឹងរងវេទនាដរាបដល់ស្លាប់ក្នុងថ្ងៃនេះហើយព្រះករុណា ។

ក៏ហេតុតែអំណាចតេជះបុញ្ញាធិការរបស់ព្រះបរមពោធិសត្វ ដែលទ្រង់អាស្រ័យនៅក្នុងគភ៌នៃព្រះរាជទេវីនោះបណ្តាលឲ្យពិភពសម្តេចអមរិន្ទឥន្ទកោសី ក្តៅក្រហាយឡើង គ្រានោះសម្តេចព្រះសហស្សនេត្រ ទ្រង់បានជ្រាបនូវហេតុនោះគ្រប់ប្រការទើបមានទេវឱង្ការ ត្រាស់ឲ្យហៅវិស្សកម្មទេវបុត្រឲ្យចូលមកគាល់ លុះមកដល់ហើយទើបទ្រង់បង្គាប់ថា នៃវិស្សកម្ម ចូរអ្នកចុះទៅកាន់ជើងភ្នំចន្ទបពតិហើយនិម្មិតនូវស្រះមួយ ព្រមទាំងឈូកមានផ្កាមានពណ៌ ៥ យ៉ាងក្នុងវនប្រទេសឲ្យជាទីសប្បាយរីករាយនឹងនិម្មិតបណ្ណសាលាមួយ ព្រមទាំងគ្រឿងបរិក្ខារសម្រាប់អ្នកបួសទុកនៅក្នុងទីនោះផង រួចហើយចូរអ្នកត្រឡប់មកវិញចុះ ឯព្រះវិស្សកម្មទេវបុត្រនោះក៏ទទួលទេវអាជ្ញាហើយ ចុះមកនិម្មិតតាមព្រះរាជឱង្ការស្រេចហើយទើបចារឹកអក្សរទុកនៅក្លោងទ្វារនោះថា ។

យោបព្វជ្ជិតុកាមោយថាសុខំគណ្ហាតុ សេចក្តីថាអ្នកឯណា ត្រូវការនឹងបួស អ្នកនោះចូរកាន់នូវគ្រឿងបរិក្ខារនេះតាមសេចក្តីសប្បាយចុះ ហើយវិស្សុកម្មក៏ត្រឡប់ទៅកាន់ទីនៅរបស់ខ្លួនវិញក្រាបបង្គំទូលសេចក្តីទាំងនោះដល់សម្តេចព្រះឥន្ទ្រាធិរាជស្តេចបានជ្រាបគ្រប់ប្រការ ។

ឯព្រះបាទមហារថរាជ កាលដែលអណ្តែតដោយរលកបន្សាត់ទៅ បានរងនូវសេចក្តីទុក្ខលំបាកក្រៃលែងលើសប្រមាណ អណ្តែតទៅហួស ៧ ថ្ងៃ ទើបបានដល់មកនគររបស់ព្រះអង្គដដែលវិញ ។

ចំណែកខាងនាងទេវីនោះសោតនាងក៏ឆ្អែតឆ្អន់ទៅដោយសេចក្តីទោមនស្ស តែរាល់ពេលឥតមានស្រាកស្រាន្តឡើយ ក្នុងថ្ងៃមួយនោះនាងក៏លីលាទៅតាមមគ្គមាគ៌ា បានឃើញនូវបណ្ណសាលាព្រមទាំងអក្សរចារឹកទុកនៅទីក្លោងទ្វារនោះនាងក៏ប្រឹងទតសព្វសេចក្តីហើយ ក៏ទ្រង់ជ្រាបថាជាស្តេចទេព្តាព្រះអង្គសាងទុកឲ្យ ទើបចូលទៅសម្នាក់អាស្រ័យក្នុងបរមសាលានោះ ហើយក៏ទ្រង់ព្រះផ្នួសបួសជាតាបសនីនៅក្នុងទីនោះ ឯនាងទេវីជាស្រីមានគភ៌បរិបូណ៌គ្រប់ខែថ្ងៃហើយ វេលានោះខ្យល់កម្មជ្ជវាតបក់កម្រើកឡើងបង្វិលគភ៌នាងហើយឲ្យទ្រង់ប្រសូតនូវព្រះរាជឱរស ដ៏ល្អមានពណ៌បីដូចជាពណ៌នៃមាសឆ្អិនក្នុងវេលាពាក់កណ្តាលអធ្រាត្រនោះ លុះព្រឹកឡើងនាងក៏ស្រង់ទឹកជម្រះព្រះមហាសត្តហើយ ឲ្យសោយនូវក្សីរធារារួចស្រេចទើបផ្តេកព្រះពោធិសត្តទុកក្នុងទីនោះ ។

ឯព្រះរាជទេវីកាលដែលនឹងកំណត់ព្រះនាមថ្វាយព្រះពោធិសត្តនោះ គឺព្រះនាងកាន់យកនូវនិមិត្តក្នុងថ្ងៃដែលប្រសូតនោះ ព្រោះថ្ងៃយប់នោះពន្លឺកែវគ្រប់យ៉ាងបណ្តាលឲ្យភ្លឺព្រោងព្រាតដាសពេញក្នុងព្រៃហិមពាន្តទាំងអស់ ទើបកាន់យកហេតុនោះមកកំណត់ជាព្រះនាមថ្វាយថា រតនបជោត ដូច្នេះ ។ ក្នុងគ្រា ១ នោះព្រះរាជទេវីនាងក៏ដាក់ពោធិសត្តឲ្យទ្រង់ផ្ទំនៅក្នុងបណ្ណសាលា ហើយព្រះអង្គនាងក៏ចូលទៅក្នុងព្រៃដើម្បីស្វែងរកមើមឈើនិងផ្លែឈើតូចធំ លុះបានហើយក៏ត្រឡប់មកអង្គុយនៅក្នុងបណ្ណសាលាវិញបរិភោគនូវផលាផលទាំងនោះតាមធម្មតា ដែលនាងប្រព្រឹត្តធ្វើយ៉ាងនេះដរាបដល់ព្រះពោធិសត្តមានព្រះជន្មាយុបាន ៥ ឆ្នាំ ។

ក្នុងថ្ងៃ ១ នោះព្រះពោធិសត្តទ្រង់ត្រាស់សួរព្រះវររាជជននីថា បពិត្រអ្នកម៉ែ បិតារបស់ខ្ញុំនោះជាអ្វី នៅក្នុងទីណា?

ព្រះមាតាបានស្តាប់ហើយ ក៏ប្រាប់ទៅវិញថាឱកូនសម្លាញ់ បិតារបស់អ្នកនោះជាស្តេចសោយរាជ្យ មាតានេះជាព្រះរាជទេវី ហើយនាងក៏និយាយរាប់រៀបរឿងពីដើមប្រាប់ព្រះរាជបុត្រដរាបដល់ចប់ ព្រះពោធិសត្តបានទ្រង់ព្រះសណ្តាប់រឿងនោះហើយ មិនអាចនឹងទប់ទល់ខ្លួនបាន ដោយអានុភាពនៃសេចក្តីកតញ្ញូទើបទូលព្រះមាតាថា បពិត្រអ្នកម៉ែ តាំងអំពីថ្ងៃនេះទៅ សូមព្រះមាតានៅចាំសាលាចុះ ខ្ញុំនឹងទៅស្វែងរកមើមឈើផ្លែឈើមកបម្រើចិញ្ចឹមអ្នក ព្រះមាតាបានស្តាប់ហើយ ទើបប្រាប់ទៅពោធិសត្វវិញដោយសេចក្តីស្នេហានឹងកូននោះថា នៃកូនសម្លាញ់អ្នកកុំចូលទៅក្នុងព្រៃឡើយ កាលបើអ្នកមានជីវិតរស់នៅ មាតាក៏ឈ្មោះថារស់នៅដែរ

ព្រោះហេតុអ្វីក៏បានជាមាតា ពោលយ៉ាងហ្នឹង ព្រោះថាខ្លួនអ្នកនៅក្មេងតូចពេកណាស់ ហេតុនោះកូនកុំទៅក្នុងព្រៃឡើយ ព្រះបរមពោធិសត្វកាលមិនបានឱកាសយ៉ាងហ្នឹងហើយ ក៏ស្ថិតនៅស្ងៀមនៅទីនោះ ។

វេលាថ្ងៃក្រោយព្រះរាជទេវីនាងក៏ស្តេចចូលទៅក្នុងព្រៃស្វែងរកផលាផលតែរាល់ ៗ ថ្ងៃ ក្នុងថ្ងៃមួយនោះព្រះពោធិសត្វក៏ចេញចាកបណ្ណសាលា ហើយទៅតាមស្នាមព្រះបាទព្រះមាតា ព្រោះបានចាំផ្លូវនិងទិសដែលមាតាស្តេចទៅតាំងពីដំបូងឡើយ ។

ថ្ងៃមួយនោះ ព្រះរាជទេវីស្តេចចេញទៅព្រៃតាំងពីព្រលឹមរកបេះផ្លែឈើបានដាក់ពេញកញ្ជើហើយ ទើបគិតថា អញនឹងត្រឡប់មកបណ្ណសាលាវិញ ហើយនាងចូលទៅឈប់ក្រោមម្លប់ដើមជ្រៃ ១ ដើម្បីបន្ទោបង់នូវសេចក្តីព្រួយកាយ រួចនាងប្រាថ្នាក្រោកឡើងចេញទៅទៀត ខណៈនោះមានយក្ខ ១ ឈ្មោះពលាហកអាស្រ័យនៅដើមជ្រៃ យក្ខនោះក៏ស្ទុះចូលមកចាប់ព្រះហស្តនាងទាញទុក នាងក៏ទតព្រះនេត្រទៅឃើញរូបយក្ខនោះហើយក៏ញ័ររន្ធត់ស្លុតខ្លាចសេចក្តីស្លាប់នោះពន់ប្រមាណ ហើយក៏នឹកដល់ព្រះមហាសត្តថា កូនសម្លាញ់អញអើយអ្នកនៅតូចណាស់ ហើយនាងទ្រង់ពិលាបសោយសោកបោកខ្លួន ទើបពោលនូវគាថាដូច្នេះថា៖

អជាថោជាធិមេបុត្តោ វសេដ្ឋោឯកោអស្សមេ
ផលាផលំអលទ្ធាន មមំធិស្វាអជយតឹ
អស្សមាធិក្ខមិត្វាន វិចរតិព្រហាវនេ
មមបុត្តំអធិស្វាន មញ្ញេហេស្សាមិជីវិតំ
សោឆ្ញកប្បណោបុត្តោ ចីរំរត្តាយរុច្ចតិ
អឌ្ឍរត្តេចរត្តេវា នធីវអវសុស្សតិ

សេចក្តីថា ឥឡូវនេះកូនអញនៅក្នុងអាស្រមតែម្នាក់ឯងរកអ្នកណាមួយ ជាទីពឹងមិនមានឡើយ មុខជានឹងមិនបានបរិភោគនូវផ្លែឈើឡើយ ហើយក៏នឹងចេញចាកអាស្រមទៅស្វែងរកអញក្នុងព្រៃធំ ព្រោះហេតុតែមិនបានឃើញអញមក អញសោតក៏មិនខានឃើញកូនរបស់អញ ហើយអាត្មាអញប្រហែលជានឹងអស់ជីវិតទៅមិនខានឡើយ ឯកូនសម្លាញ់អញសោតក៏នឹងនៅកំព្រាតែម្នាក់ឯងនឹងស្រែកយំរកម្តាយទាំងយប់កណ្តាលអធ្រាត្រដរាបដល់ហាបហាត់បាត់សំឡេងទៅ ដូចជាទឹកក្នុងស្ទឹងដែលហួតហែងនោះឯងមិនលែងឡើយ ។

គ្រានោះព្រះបរមពោធិសត្តអង្គុយនៅចាំព្រះមាតាតាំងពីព្រឹករហូតដល់វេលាល្ងាច មិនឃើញព្រះមាតាត្រឡប់មក ទើបគឹតរំពឹងថា ពេលនេះព្រះអាទិត្យអស្តង្គតរលត់បាត់រស្មីទៅហើយ ចុះព្រះមាតារបស់អញហេតុអ្វីក៏បាត់យូរដល់ម្ល៉េះប្រហែលជាមានអ្វីមួយបៀតបៀនមិនខានឡើយ លុះគិតដូច្នេះហើយក៏ក្រោកឡើងចាកបណ្ណសាលា ស្រែកបង្ហូករកហៅព្រះមាតាថា អ្នកម៉ែៗ ដូច្នេះ ទៅក្នុងទីទៀបមាត់ស្ទឹងនិងព្រៃញាតស្បាតរហូតដល់ជើងភ្នំធំនិងទីដទៃ ៗ

ឯព្រះពោធិសត្តប្រាសមាតា ទ្រង់សោយទុក្ខវេទនាប្រៀបដូចកូនសុវណ្ណហង្សដែលប្រាសចាកមេ កាលបើពុំឃើញព្រះមាតាហើយក៏ចូលទៅកាន់ដើមជ្រៃដែលយក្ខចាប់ព្រះមាតាទុកនៅនោះ ។

ឯព្រះរាជទេវីសិរិរតនអាភា ទ្រង់ជ្រាបថា ព្រះមហាសត្តតាមមករក ទើបស្រែកប្រាប់ទៅកូនថា នែកូនសម្លាញ់ម្ដាយ ៗ នៅឯណេះហើយ ៗ ព្រះពោធិសត្តក៏ស្ទុះចូលទៅរកមាតា ដល់ហើយក៏ឃើញមាតាអង្គុយជិតមហាយក្ខ ព្រះអង្គក៏មានព្រះហឫទ័យសោមនស្សត្រេកអរ ហាក់ដូចជាព្រះអង្គបានត្រាស់ជាព្រះពុទ្ធក្នុងថ្ងៃស្អែក ព្រះមហាសត្តក៏ខិតចូលទៅជិតមហាយក្ខហើយនិយាយអង្វរយក្ខនោះថា បពិត្រមហាយក្ខ សូមអញ្ជើញអ្នកទំពារនូវសាច់ឈាមនឹងបេះដូងរបស់ខ្ញុំចុះ សូមតែអ្នកប្រោសប្រណីលែងមាតាខ្ញុំឲ្យរួចជីវិតចេញទៅជាឆាប់ រួចទើបពោលនូវព្រះគាថា ដូច្នេះថា

**ខាទមេមហាយក្ខអានុភាវ មាតុអត្ថាយជហាមិជីវិតំ**

**វុជិរំមេហទយំមំសំខាទ ខាទាហិមំបតិមុញ្ចមាតរំ**

សេចក្ដីថា បពិត្រមហាយក្ខ អ្នកជាបុគ្គលមានអានុភាពធំខ្ញុំសូមលះបង់នូវជីវិតរបស់ខ្ញុំជំនួសព្រះមាតា សូមអ្នកបរិភោគនូវឈាមនិងបេះដូងនិងសាច់របស់ខ្ញុំចុះ ចូរអ្នកបរិភោគនូវរូបខ្ញុំទាំងមូលឲ្យអស់ចុះ ហើយសូមមេត្តាលែងមាតាខ្ញុំចេញទៅ ។

ព្រះពោធិសត្តនិយាយយ៉ាងនេះហើយ ទើបដើរចូលទៅជិតនៃមហាយក្ខ រួចនិយាយថា បពិត្រស្ដេចយក្ខ អ្នកអាណិតខ្ញុំ ៗ សូមឲ្យអ្នកទំពារស៊ីនូវខ្លួនខ្ញុំទៅ សូមតែលែងមាតាខ្ញុំក្នុងវេលានេះកុំខានឡើយ ។

ទើបមហាយក្ខនោះឆ្លើយទៅកាន់ពោធិសត្តវិញថា នែមហាបុរស បើអ្នកនិយាយយ៉ាងហ្នឹងពិតមែន ចូរអ្នកពុះនូវទ្រូងរូងយកបេះដូងនឹងសាច់មកឲ្យយើងស៊ីឥឡូវនេះមើល ឯបរមពោធិសត្ត ឮដូច្នោះហើយ ទើបមកគិតក្នុងព្រះអង្គថាចុះអញនឹងបានកាំបិតអំពីទីណាអេះ នឹកយ៉ាងហ្នឹងហើយទើបងើបងើយខំសម្រឹងព្រះស្មារតីសម្លឹងមើលទៅឯអាកាស ហើយត្រាស់នូវបាទព្រះគាថាដូច្នេះថា

**កតញ្ញុតាយតេជេន ពុទ្ធោហោមិអនាគតេ**

**ឯតេនសច្ចវជ្ជេន សត្ថំបតតុមេមុខា**

សេចក្ដីថា ខ្ញុំសូមប្រាថ្នាជាព្រះពុទ្ធមួយព្រះអង្គក្នុងកាលជាអនាគតខាងមុខ ដោយតេជានុភាពនៃចិត្តកតញ្ញូរបស់ខ្ញុំនេះសូមកាំបិតធ្លាក់ចុះមកក្នុងទីចំពោះមុខខ្ញុំកុំខានឡើយ ដោយពាក្យសច្ចនេះ ។

ពោលយ៉ាងនេះមិនទាន់ផុតពាក្យសច្ចវាចានោះវេលាណា កាំបិតសស្ត្រាដ៏មុតធ្លាក់ចុះមកអំពីទីកណ្ដាលអាកាសមកចំពោះនៅមុខនៃព្រះពោធិសត្ត ជាលំដាប់ស្មើនៃពាក្យសច្ចវាទី

នោះឯង ហើយព្រះមហាសត្វនិកាយនិងយក្ខនោះទៀតថា បើខ្ញុំមុខជានឹងបានត្រាស់ជាព្រះពុទ្ធក្នុងកាលខាងមុខ ខ្ញុំសូមថ្វាយបង្គំលាព្រះមាតានឹងស្លាប់ សូមអ្នកឲ្យនូវជីវិតរបស់ខ្ញុំដល់ព្រះមាតាខ្ញុំកុំខានឡើយ ។ គ្រានោះព្រះមាតាក៏អង្វរឃាត់ព្រះពោធិសត្វកុំឲ្យធ្វើដូច្នោះ ឯព្រះពោធិសត្វសោតអ្នកតម្កល់នូវពាក្យព្រះមាតាលើត្បូងលើកទុកហើយក៏ពុះនូវទ្រូងរបស់ព្រះអង្គដោយសស្ត្រាដ៏មុត ហើយចាប់យកនូវបេះដូងទាញចេញមកតម្កល់លើត្បូងទើបពោលព្រះគាថាដូច្នេះថា ។

**កតញ្ញុតាយតេជេន ពុទ្ធោ ហោមិ អនាគតេ**

**ហទយំ ខាទ តុម្ហំ មា មេ យក្ខ ជីវិយតុ**

សេចក្តីថា ខ្ញុំសូមឲ្យបានត្រាស់ជាព្រះពុទ្ធមួយព្រះអង្គក្នុងកាលខាងមុខ ដោយអំណាចធម៌កតញ្ញូកតវេទីរបស់ខ្ញុំនេះបពិត្រមហាយក្ខ អញ្ជើញអ្នកពិសានូវបេះដូងរបស់ខ្ញុំចុះ ហើយខ្ញុំសូមជីវិតរបស់ខ្ញុំកុំអាលឲ្យរលត់អស់មុនឡើយ ព្រះបរមពោធិសត្វសម្តែងនូវព្រះគាថាដូច្នេះហើយ ទ្រង់ប្រាថ្នានឹងឲ្យនូវហទយវត្ថុដល់យក្ខនោះដោយគោរព ទើបលើកបេះដូងនោះតម្កល់លើដៃយក្ខហើយទ្រង់ប្រកាសសេចក្តីឲ្យជាក់ច្បាស់ថា នែមហាយក្ខ ខ្ញុំឯងឲ្យសាច់ដែលមានតម្លៃស្មើជីវិតនេះជាទានមដល់អ្នក ខ្ញុំមិនប្រាថ្នាសម្បត្តិបរមចក្រពត្រាធិរាជ ឬសម្បត្តិព្រះឥន្ទសម្បត្តិព្រះព្រហ្ម និងព្រះបច្ចេកពុទ្ធឡើយ ឯផលដែលខ្ញុំឲ្យជីវិតនេះ ខ្ញុំសូមឲ្យបានត្រាស់ជាព្រះសម្មាសម្ពុទ្ធ ១ អង្គក្នុងកាលខាងមុខនឹងបានស្រោចស្រង់សត្វនិករដែលលង់លិចទៅក្នុងសមុទ្ទសាគរពោលគឺភពទាំង ៣ ប្រការ ឲ្យឡើងកាន់សុវណ្ណនាវាពោលគឺព្រះសទ្ធម្ម នឹងនាំចេញចាកសំសារភព ចម្លងទៅកាន់ត្រើយគឺព្រះនិព្វាន ដែលជាស្ថានក្សេមក្សាន្តនិរាសភ័យទាំងពួង ព្រះមហាសត្វប្រកាសយ៉ាងនេះហើយ ក៏ប្រាប់ទៅមហាយក្ខឲ្យបរិភោគនូវសាច់បេះដូងនោះតាមចេតនា ឯមហាយក្ខក៏ទទួលយកសាច់នោះទៅបរិភោគទាំងអស់មិនមានសល់ហើយនាំយកមាតារបស់ពោធិសត្វនោះមកប្រគល់ឲ្យពោធិសត្វវិញ ។

ព្រះបរមពោធិសត្វបានជួបនឹងព្រះមាតាហើយក៏នាំទៅឲ្យគង់នៅក្រោមម្លប់ឈើ ១ ទើបក្រាបថ្វាយបង្គំទូលព្រះមាតាថាបពិត្រព្រះរាជជននីម្ចាស់ ចាប់ដើមតាំងអំពីខ្ញុំមកជ្រកនៅក្នុងព្រះឧទរអ្នកមករហូតដល់ថ្ងៃនេះ សេចក្តីភ្លាំងភ្លាត់របស់ខ្ញុំដោយកាយវាចាចិត្តឯណា ១ សូមព្រះមាតាមេត្តាប្រោសប្រណីប្រទានទោសនោះដល់ខ្ញុំដោយសេចក្តីការុញ្ញភាពរបស់អ្នកចុះ លុះពោលពាក្យប៉ុណ្ណឹងហើយក៏បាត់បាត់សំឡេងឈឹង ទន់ទោព្រះអង្គក្រាបចុះទៅត្រង់ទីចំពោះព្រះភក្ត្រព្រះមាតា ។

ចំណែកសម្តេចព្រះវររាជជននីទ្រង់បានទតព្រះនេត្រឃើញព្រះមហាសត្វភាំងបាត់ ព្រះស្មារតីដូច្នោះហើយ នាងក៏ក្រោកឡើងត្រកងចាប់ព្រះហស្តថ្នមព្រះអង្គពោធិសត្វមកផ្ទប់នឹងព្រះឱរាតន៍ មានព្រះហឫទ័យក្តៅផ្សារហាក់ដូចជានឹងបែកថ្លើមចេញជាពីរភាគ ហើយមិនអាចទប់ទល់នូវសេចក្តីសោកនោះបានឡើយ ហើយនាងក៏យកព្រះហស្តទាំងពីរមកឱបក្រសោប

ថ្ពមព្រះឱរសមកដាក់ផ្ដេកផ្ទិតជិតនឹងព្រះឱរា ហើយទ្រង់ព្រះពិលាបសោយសោកជាគាថាដូច្នេះថា ៖

បតិតោឆូនមេបុត្តោ សុរិយោវិយមហីតលេ
បតិតោជានិមេបុត្តោ ចន្ទោវបតិតោឆមា
ឧដ្ឋេហិបុត្តមាសយេ ឧយ្ហន្តេហាឧយំមម
តយិមតេមវិស្សាមិ កាចំជីវាមិឯកិកា
អជាថាជានិហំបុត្ត បុត្តឧដ្ឋាយថាមិគី
អរញ្ញេវិចវិស្សាមិ វនេហិចមវិស្សាមិ
បព្វតានិវជានិច រុក្ខវិមានភូមដ្ឋា
អាកាសដ្ឋទេវតាច ជលថលាចយេទេវា
ឥន្ទទេវាសព្រហ្មកា អញ្ជលីតេឧមស្សាមិ
ទិប្បំបុត្តំបមុញ្ចថ ទិប្បំបុត្តំបមុញ្ចថ

សេចក្ដីថា ឱកូនអញដួលក្រាបនៅលើផែនដីហើយដូចព្រះអាទិត្យឬព្រះចន្ទដែលអស់អំណាចរស្មីហើយ ធ្លាក់ចុះមកលើផែនប្រឹថពី ឱកូនសម្លាញ់ម្ដាយ ចូរអ្នកក្រោកឡើងកុំដេកនៅឡើយ សាច់បេះដូងរបស់ម្ដាយភ្លើងគឺសេចក្ដីទុក្ខនឹងឆេះឥឡូវនេះហើយ កាលបើកូនសម្លាញ់អ្នកស្លាប់ទៅហើយម្ដាយក៏នឹងស្លាប់ជាមួយមិនខានឡើយ ម្ដាយនឹងរស់នៅឯណាបានតែម្នាក់ឯង នែបុត្រជាទីស្រឡាញ់បំផុតរបស់ម្ដាយ ឥឡូវនេះម្ដាយរកទីពឹងពុំនាក់មិនមានឡើយ ដូចមេម្រិគដែលព្រាត់ប្រាសចាកកូន ម្ដាយនឹងត្រាច់ទៅក្នុងព្រៃនឹងក្ស័យជីវិតដល់នូវមរណកាលក្នុងដងនៃព្រៃមិនខាន ។

មួយសោតទេវតាទាំងឡាយ ដែលលោកស្ថិតនៅក្នុងភ្នំនឹងព្រៃទាំងឡាយ និងដើមឈើវិមានភូមិស្ថានទាំងឡាយឬទេវតាដែលស្ថិតនៅលើអាកាសស្ថាននិងជលស្ថាននិងថលស្ថាន ទាំងឡាយឯណា និងសម្ដេចឥន្ទ្រាធិរាជព្រមទាំងមហាព្រហ្ម ខ្ញុំម្ចាស់សូមប្រណម្យនមស្ការនូវទេវតាទាំងឡាយនោះសូមលោកទាំងឡាយអញ្ជើញមកជួយដោះទុក្ខកូនខ្ញុំ ឲ្យរួចផុតចាកសេចក្ដីស្លាប់ក្នុងកាលឥឡូវនេះកុំខាន ៗ ព្រះទេវីទ្រង់ឱបនូវព្រះឱរសរបស់នាងហើយទ្រង់ព្រះពិលាបដោយន័យយ៉ាងនេះ ។

គ្រានោះពិភពនៃសកទេវរាជ ក៏បណ្ដាលអាការឲ្យជាហេតុខុសចាកធម្មតា ដោយអំណាចនៃសេចក្ដីកតញ្ញូរបស់ព្រះមហាបុរសរតន៍ សម្ដេចព្រះសហស្សន័យទ្រង់រំពឹងមើលហើយទ្រង់ជ្រាបច្បាស់នូវហេតុនោះទើបស្ដេចចុះចាកសគ្គស្ថានទេវលោក មកស្ថិតនៅលើអាកាសត្រង់ទីដែលមហាយក្ខស្ថិតនៅនោះ ហើយទ្រង់សួរទៅយក្ខនោះថា នែពលាហាកយក្ខ

ហេតុអ្វីក៏ឯងធ្វើអំពើកម្មមានកម្លាំងរហ័សយ៉ាងនេះ នែមហាយក្ខថាបើមហាបុរសនេះមិនបានរស់ឡើងឥឡូវនេះទេអញនឹងទម្លាយនូវក្បាលរបស់អ្នកឲ្យបែកជា ៧ ភាគ ដោយវជិរាវុធនេះមិនខាន ពលាហកយក្ខ បានស្តាប់ដូច្នោះហើយ មានចិត្តខ្លាចស្លាប់នោះក្រៃពេក ទើបស្ទុះចូលទៅលើកព្រះបរមពោធិសត្តឡើងហើយក៏លាបស្រឡាបដោយឱសថទិព្វវិសេស ១ រំពេចព្រះពោធិសត្តក៏បានភ្ញាព្រះស្មារតីឡើង ។

ឯសម្តេចព្រះវររាជទេវីនាងក៏ទ្រង់អធិដ្ឋានថា ៖

**កតញ្ញុតាយយុត្តោសោ ពុទ្ធោហោតិអនាគតេ**

**មម សច្ចានុភាវេន ទិប្បំជីវតុឱរសោ ។**

សេចក្តីថា ព្រះឱរសរបស់អញនោះជាអ្នកតាំងមាំក្នុងធម៌កតញ្ញូ មុខជានឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគតកាលដោយពិត សូមឲ្យឱរសរបស់ខ្ញុំរស់រួចជីវិតឡើងក្នុងកាលឥឡូវនេះដោយអានុភាពនៃសេចក្តីពិតរបស់ខ្ញុំម្ចាស់កុំខានឡើយ ។

កាលបើចប់ពាក្យសច្ចាធិស្ឋានហើយ ព្រះមហាបុរសក៏មានពណ៌សម្បុរដ៏ផូរផង់ ហាក់ដូចជាពណ៌ទិព្វវិសេស ដោយអំណាចនៃសេចក្តីអធិស្ឋានរបស់ព្រះរាជទេវី លុះចប់សេចក្តីអធិស្ឋានជាគម្រប់ពីរព្រះបរមពោធិសត្តក៏មានដង្ហើមចេញចូលបានហើយប្រែព្រះអង្គត្រឡប់ទៅមកខាងឆ្វេងខាងស្តាំ លុះចប់ពាក្យសច្ចវាទីជាគម្រប់ ៣ ព្រះពោធិសត្តមានព្រះស្មារតីដឹងប្រាកដហើយ ទើបក្រោកឡើងក្រាបថ្វាយបង្គំសម្តេចព្រះវររាជទេវីព្រះជននីរបស់ព្រះអង្គក្នុងកាលគ្រានោះ ។

តមត្ថំបកាសេន្តោសត្ថាអាហ ព្រះបរមលោកនាថសាស្តាចារ្យ ទ្រង់ប្រកាសនូវសេចក្តីទាំងនោះមកដល់ត្រឹមនេះហើយទើបទ្រង់សម្តែងនូវព្រះគាថានេះថា ៖

**និព្ពេគោឧជ្ជហិត្វាន វឌ្ឍិត្វាសកមាតរំ**

**ឯកមន្តេនិសីទិត្វា អាវជ្ជកុណាមត្តនោ**

**ឯវំអាជ្ជមានោសោ អកម្បិជរណីតលា**

**សាគរេបិសំខុព្ភតិ សិនេរុតត្ថឱនមិ**

**ចាតុមហារាជិកានេវា តាវតឹសាចយាមិកា**

**តុសិតាចេវយេនេវា និម្មានរតិយេវច**

**បរនិម្មិតវសវត្តី យេព្រហ្មាបិចនេវតា**

**អានន្ទតាបមុទិតា និសានិសំអកំសុតេ**

**និព្វមណ្ឌារវបុប្ផំ បទុមំចាវិច្ចត្តកំ**

ជិសាជិសំឱកិរីសុ ឯកតលេឯរាមរុំ
ចម្បកំសរលជិបំ ជាតបុជាតតេតលំ
ជិសាជិសំឱកិរីសុ កុម្ភាកុម្ភជ្ជទេវតា
សព្វេទេវាសមាគតា បូជយឹសុឯរុត្តមំ
បូជយន្តាចយេទេវា ឥជំវចនមព្រវិ
សាធុសាធុមហាវីរ កាតវេជីឯរុត្តម
អចិរេទេវកាលេឯ ពុទ្ធោលោកេភវិស្សតិ

ប្រែជាសេចក្តីថា ព្រះមហាបុរសព្រះអង្គបានប្រាសចាករោគាពាធហើយ ក៏ក្រោកឡើងឱនកាយថ្វាយបង្គំព្រះជននី អង្គុយនៅក្នុងទីដ៏សមគួរមួយ ហើយទើបនឹករឭកដល់គុណគឺសេចក្តីល្អរបស់ខ្លួន កាលដែលទ្រង់រំពឹងយ៉ាងហ្នឹងហើយទីនោះព្រះធរណីក៏កម្រើកញាប់ញ័រសាគរសមុទ្ទក៏បន្លឺសព្ទសំឡេងលាន់ឮគឹកកងរំពង ទាំងភ្នំសិនេរុរាជសោតក៏ទន់ទោឱនទៅក្នុងទីនោះ ឯទេវតាក្នុងជាន់ចាតុម្មហារាជិកានិងតាវត្តិង្ស យាមា តុសិត និម្មារតី និងបរនិម្មិតវសវតី រហូតដល់ទេវតាក្នុងជាន់មហាព្រហ្មសោតក៏មានសេចក្តីសប្បាយរីករាយ តែរាល់គ្នាដោយសោមនស្សចិត្ត ទាំងផ្កាទិព្វមណ្ឌារវបារិច្ឆតកបទុមជាតិសោត ក៏ធ្លាក់ចុះពោយរាយទូទៅទាំងទិសតូចទិសធំសព្វកន្លែង ពពួកជនទូទៅទាំងអស់ក៏រោយរាយនូវគ្រាប់ខ្យាច់និងផ្កាឈើផ្សេងៗ មានផ្កាស្រស់នឹងផ្កាំរាំងផ្កាខ្ទឹងនិងផ្កាបុនាគនិងផ្កាចម្ប៉ាជាដើម ឲ្យផ្សាយក្លិនរហូតទៅក្នុងអាកាសនិងទិសានុទិស ចំណែកទេវតាទាំងឡាយទាំងពួងមានភូមទេវតាជាដើម ក៏មកប្រជុំគ្នាធ្វើសក្ការបូជា មហាបុរសជានរុត្តមក្សត្រ លុះបានបូជារួចហើយក៏ពោលសរសើរព្រមគ្នាថា នរុត្តមបពិត្រព្រះមហាបុរសជានរុត្តមលោក ព្រះអង្គមានព្យាយាមធំ ទ្រង់បានសងគុណព្រះជននីដោយកតវេទិតាធម៌រួចហើយជាកិច្ចដ៏ឧត្តមប្រពៃពេកណាស់ ព្រះអង្គមុខជានឹងបានត្រាស់ជាព្រះសម្មាសម្ពុទ្ធក្នុងលោកនេះមិនខានឡើយ ។

លំដាប់នោះ ទើបពលាហកយក្ខក្រាបថ្វាយបង្គំព្រះបរមពោធិសត្តសូមខមាទោសស្រេចហើយ ក៏ទេវតាទាំងឡាយមានសម្តេចសក្កទេវរាជជាដើម និម្មិតនូវសុវណ្ណសិវិកា (វមាស) អញ្ជើញព្រះរាជទេវីនិងព្រះបរមពោធិសត្តឲ្យគង់លើវមាសនោះហើយ ដង្ហែរទៅកាន់ស្រុកមេឃវតី ក្នុងវេលារាត្រីកណ្តាលអធ្រាត្រ ហើយឲ្យគង់នូវលើរតនបញ្ជាសនព្វដ៏ខាងលើប្រាសាទ ៧ ជាន់ ទើបទេវតាទាំងនោះថ្វាយបង្គំលាត្រឡប់ទៅកាន់ទីលំនៅរបស់ខ្លួនៗ រាល់គ្នាវិញ ។

គ្រានោះសម្តេចព្រះបាទមហារថរាជ ព្រះអង្គក៏បានជួបប្រទះនឹងបុត្រភរិយា ហើយទ្រង់ក៏ស្គាល់ជាក់ប្រាកដជាព្រះរាជទេវីនិងព្រះពោធិសត្ត ស្តេចក៏មានព្រះហឫទ័យសោមនស្សជាទីបំផុតចិត្តពេកណាស់ ហើយព្រះអង្គទ្រង់លើករាជសម្បត្តិឲ្យទៅរាជឱរសរបស់ព្រះអង្គសោយ

រាជជំនួស ឯព្រះបរមពោធិសត្វ ទ្រង់បានរាជាភិសេកសោយនូវបញ្ចកាមគុណតាមសមគួរ ហើយ ទ្រង់ក៏ឲ្យទានអស់ ១ ខែទើបលើករាជសម្បត្តិនោះបង្វែរថ្វាយព្រះវររាជបិតាវិញ ដើម្បីនឹងឲ្យព្រះបិតាមាតាទ្រង់ស្រង់តាក់តែងព្រះអង្គនិងសោយឲ្យស្រួលក្នុងព្រះរាជហឫទ័យទើបថ្វាយបង្គំសូមខមាទោសនិងសូមព្រះរាជានុញ្ញាតដើម្បីចេញទៅទ្រង់ព្រះផ្នួស ហើយទ្រង់លាអស់រាជវង្សានុវង្សទាំងឡាយគ្រប់គ្នា ឯមហាជនទាំងឡាយនោះ ក៏កើតសេចក្ដីសោកស្ដាយព្រះពោធិសត្វជាទីបំផុតពេក ហើយព្រះអង្គក៏ស្ដេចចេញចាកនគរទៅតែម្នាក់ឯង បែរព្រះភក្ត្រាចំពោះទៅកាន់ភ្នំហិមពាន្តហាក់ដូចជាកូនរាជហង្សហើរចេញអំពីកំពូលភ្នំធំ ។

តមត្ថំបកាសេន្ដោសត្ថាអាហ ព្រះបរមសាស្ដាចារ្យ កាលទ្រង់ប្រកាសនូវរឿងទាំងនោះស្រេចហើយ ទើបទ្រង់ត្រាស់នូវគាថានេះថា៖

**យតោវជ្ជំលភិត្វាន        មាសំជានំអទាសិសោ**

**បិតុរជ្ជំនិយាទេត្វា        ហិមវន្តំនិវត្តយិ**

សេចក្ដីថា កាលណាដែលព្រះមហាសត្វ ស្ដេចបានរាជសម្បត្តិរួចហើយទ្រង់ក៏បានបរិច្ចាគនូវទានប្រមាណ ១ ខែហើយ ទើបទ្រង់បង្វែរាជសម្បត្តិនោះថ្វាយដល់ព្រះរាជបិតាវិញរួចទើបព្រះអង្គក្រាបថ្វាយបង្គំសូមព្រះរាជានុញ្ញាតនឹងត្រឡប់ទៅកាន់ព្រៃហិមពាន្តវិញ ដើម្បីនឹងបួសជាឫសី ក៏ព្រះបរមពោធិសត្វទ្រង់បព្វជ្ជាជាឫសីរួចហើយវេលាណាព្រះអង្គក៏ចម្រើនអភិញ្ញា ៥ និងសមាបត្តិ ៨ ឲ្យបរិបូណ៌ឡើងក្នុងសន្តានទ្រង់ក៏រក្សាគុណវិសេសទាំងនោះមិនឲ្យសាបសូន្យឡើយ លុះអស់ព្រះជន្មាយុទៅក៏បានឡើងទៅកើតក្នុងស្ថានព្រហ្មលោក ។

ឯសម្ដេចព្រះបាទមហារថរាជនិងព្រះនាងសិរិរតនអាភានិងមហាជនក្នុងនគរនោះ ក៏បានតម្កល់នៅក្នុងឱវាទនៃព្រះបរមពោធិសត្វនោះបានធ្វើនូវបុញ្ញរាសីទាំងឡាយ មានទានជាដើម កាលបើអស់អាយុរាល់គ្នាទៅវេលាណាហើយ ក៏បានឡើងទៅកើតក្នុងស្ថានព្រហ្មលោកគ្រប់គ្នា ។

**សត្ថាឥមំធម្មទេសនំអាហរិត្វា**

**សច្ចានិបកាសេត្វាជាតកំសមោធានេសិ**

សម្ដេចព្រះបរមគ្រូទ្រង់នាំនូវធម្មទេសនារឿងនេះមកហើយ ទើបទ្រង់ប្រកាសនូវអរិយសច្ចទាំង ៤ ប្រការលុះចប់ហើយវេលាណា មាតុបោសក ក៏បានលុះសោតាបត្តិផលជាអរិយបុគ្គលក្នុងពុទ្ធសាសនមណ្ឌល ទើបព្រះបរមសាស្ដាទ្រង់ផ្ទឹំនូវជាតកមកប្រាប់ថា នាងសិរិរតនអាភាជាមាតាពោធិសត្វនោះបានមកជានាងមហាមាយាទេវី ព្រះបាទព្រះមហារថរាជជាបិតាពោធិសត្វនោះបានមកជាព្រះបាទសិរិសុទ្ធោទនមហារាជ ព្រះសកទេវរាជបានមកជាព្រះអនុរុទ្ធត្ថេរ ពលាហកយក្ខបានមកជាព្រះអង្គុលិមាលត្ថេរ ព្រះមហាសត្វរតនបជោត នោះមិនគឺអ្នកដ៏ទៃឡើយ គឺអង្គអញតថាគតជានាយកនេះឯង អស់លោកទាំងឡាយចូរទ្រទ្រង់នូវព្រះជាតក

នេះទុកដោយប្រការយ៉ាងនេះ ។

*ចប់រតនបដោតជាតក*

ព្រះឧត្តមមុនី អ៊ុំ ស៊ូរ អាចារ្យព្រះរាជបណ្ណាល័យកម្ពុជា

ប្រែនិងរៀបរៀង

ប្រភព: *ទស្សនាវដ្ដីកម្ពុជសុរិយា ឆ្នាំ១៩៣២*


**Website: BVDCC.org**

**E-mail: Chhenchhoun@gmail.com**

**YouTube: Vipassana Dhurak Buddhist Centre**

**YouTube: ពុទ្ធមណ្ឌលវិបស្សនាធុរៈ នៃព្រះរាជាណាចក្រកម្ពុជា**